# សិទ្ធិ ទទួលព័ត៌មាន



ខែឧសភា ឆ្នាំ២០២២

ផលិតដោយៈ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

គាំទ្រដោយៈ

USAID
ជំនួយពីពលរដ្ឋអាមេរិក

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅប្រទេសកម្ពុជា។ ទស្សនៈវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាននិងត្រូវបានផ្តល់អំណាចដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ម.ស.ម.ក លើកកម្ពស់នីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានស្វាគមន៍ និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ រូបសញ្ញាសម្គាល់របស់ ម.ស.ម.ក គឺរូបសត្វព្រាបពណ៌សកំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃ ដែលតំណាងឱ្យគោលការណ៍សន្តិភាព និងសេរីភាព។

## សេចក្តីថ្លែងអំណរគុណ

មេរៀនស្តីពីសិទ្ធិទទួលព័ត៌មាននេះអាចកើតចេញជារូបរាងឡើងដោយសារមានការគាំទ្រដោយសប្បុរសអំពីទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក។ ខ្លឹមសារនៃសៀវភៅនេះគឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិកឡើយ។

## អំពីមេរៀនស្តីពីសិទ្ធិទទួលព័ត៌មាន

មេរៀនស្តីពីសិទ្ធិទទួលព័ត៌មាននេះត្រូវបានផលិតឡើងជាផ្នែកមួយរបស់គម្រោង “បង្កើនការគោរពសិទ្ធិនៅកម្ពុជា” ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីការទទួលព័ត៌មាននៅក្នុងប្រទេស។ មេរៀននេះពណ៌នាអំពីសិទ្ធិទទួលព័ត៌មាន និងសារៈសំខាន់នៃសិទ្ធិនេះ។ មេរៀននេះក៏បានដាក់បញ្ចូលក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន រួមទាំងច្បាប់ជាតិ អន្តរជាតិ និងរបៀបដែលរដ្ឋអាចការពារ និងលើកកម្ពស់សិទ្ធិនេះផងដែរ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈ៖

អាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ (០) ២៣ ៧២៦ ៩០១

គេហទំព័រ៖ www.cchrcambodia.org

BY NC SA

## មាតិកា


សិទ្ធិទទួលព័ត៌មាន ........ ១

១. ក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាន ........ ២

១.១ ច្បាប់អន្តរជាតិ ........ ២

១.២ ច្បាប់ជាតិ ........ ២

២. ស្ថាប័នសាធារណៈ និងកាតព្វកិច្ចរបស់ខ្លួនក្រោមគោលការណ៍នៃសិទ្ធិទទួលព័ត៌មាន ........ ៣

២.១ តើស្ថាប័នសាធារណៈជាអ្វី ហើយព័ត៌មានប្រភេទណាដែលត្រូវតែបញ្ចេញ? ........ ៣

២.២ គោលការណ៍នៃសិទ្ធិទទួលព័ត៌មាន ........ ៤

៣. ទំនាក់ទំនងរវាងសិទ្ធិទទួលព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ ........ ៦

៤. ហេតុអ្វីសិទ្ធិទទួលព័ត៌មានមានសារៈសំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់យើង? ........ ៦

៤.១ ការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ ........ ៧

៤.២ គណនេយ្យភាព ........ ៧

៤.៣ ឥទ្ធិពលលើការប្រឆាំងអំពើពុករលួយ ........ ៧

៤.៥ ការអភិវឌ្ឍ ........ ៧

៦. តើរដ្ឋអាចការពារសិទ្ធិទទួលព័ត៌មានដោយរបៀបណា? ........ ៨

សំណួរសាកល្បង........ ១០

# សិទ្ធិទទួលព័ត៌មាន

# សិទ្ធិទទួលព័ត៌មាន



សិទ្ធិទទួលព័ត៌មានគឺជាផ្នែកមួយនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងការស្វែងរក ទទួល និងចែកចាយព័ត៌មាននិងគំនិតនានា។ សិទ្ធិទទួលព័ត៌មានគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ហើយត្រូវបានផ្សារភ្ជាប់ជាមួយនឹងសិទ្ធិដទៃផ្សេងទៀតជាច្រើនរួមទាំងសេរីភាពនៃគំនិត មនសិការ សាសនា សេរីភាពក្នុងការជួបប្រជុំ និងសេរីភាពខាងសមាគម។ សិទ្ធិទទួលព័ត៌មានក៏ត្រូវបានផ្សារភ្ជាប់ទៅនឹងអភិបាលកិច្ចល្អផងដែរ ដូចជាតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ហើយមានសារៈសំខាន់ណាស់ក្នុងការកសាងទំនុកចិត្ត និងភាពជឿជាក់លើរដ្ឋាភិបាល។

សិទ្ធិទទួលព័ត៌មានគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស ដែលចែកចេញជាពីរផ្នែកដូចជា៖

- **សិទ្ធិសកម្ម**

សិទ្ធិទទួលព័ត៌មានកំណត់អំពីកាតព្វកិច្ចជាវិជ្ជមានរបស់ស្ថាប័នសាធារណៈក្នុងការផ្តល់ឱ្យ បោះពុម្ពផ្សាយ និងផ្សព្វផ្សាយព័ត៌មានដែលមានសារៈសំខាន់ដល់សាធារណជន។ ព័ត៌មានត្រូវតែមានភាពងាយស្រួលក្នុងការស្វែងរក រួមមានព័ត៌មានអំពីសកម្មភាពសំខាន់ៗ ថវិកាជាតិ គោលនយោបាយ និងផែនការរបស់ស្ថាប័នសាធារណៈ។ ការធ្វើបែបនេះអាចឱ្យរដ្ឋាភិបាលមានតម្លាភាព និងផ្តល់ចំណេះដឹងដល់សាធារណជនអំពីមុខងារស្ថាប័នទាំងនេះ ដោយអនុញ្ញាតឱ្យពួកគេចូលរួមក្នុងកិច្ចការសាធារណៈផងដែរ។

- **សិទ្ធិប្រតិកម្ម**

សិទ្ធិទទួលព័ត៌មានអនុញ្ញាតឱ្យបុគ្គលគ្រប់រូបស្វែងរក ស្នើសុំ និងទទួលព័ត៌មានពីមន្ត្រីសាធារណៈអំពីភារកិច្ច សកម្មភាពដែលកំពុងអនុវត្ត និងឯកសារទាំងឡាយ។ ព័ត៌មានភាគច្រើនដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈគួរតែត្រូវបានផ្តល់ជូនតាមការស្នើសុំ ប៉ុន្តែព័ត៌មានមួយចំនួនអាចត្រូវបានបដិសេធដោយស្របច្បាប់ ដើម្បីការពារឯកជនភាព សន្តិសុខជាតិ ឬផលប្រយោជន៍ពាណិជ្ជកម្មជាដើម។

## ១. ក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាន

### ១.១ ច្បាប់អន្តរជាតិ




មាត្រា១៩ នៃ**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ចែងថា *"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការ **ស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា** ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"*

មាត្រា១៩ នៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ដែលកម្ពុជាជាភាគីនោះ តម្រូវឱ្យរដ្ឋភាគីធានានូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងព័ត៌មាន រាប់បញ្ចូលទាំងសិទ្ធិក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និង *"សិទ្ធិក្នុងការ**ស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា** ដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។"*

### ១.២ ច្បាប់ជាតិ

#### ១.២.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ")

**មាត្រា៣១** នៃរដ្ឋធម្មនុញ្ញផ្តល់ធម្មនុញ្ញភាពដល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយដែលកម្ពុជាបានផ្តល់សច្ចាប័ន ដែលភាគច្រើនមានចែងអំពីសិទ្ធិទទួលព័ត៌មាន។

**មាត្រា៤១** ការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សារព័ត៌មាន បោះពុម្ពផ្សាយ និងជួបប្រជុំ។

#### ១.២.២ ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ ("ច្បាប់សារព័ត៌មាន")



**មាត្រា១** *ធានារ៉ាប់រងសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយ* ស្របតាមមាត្រា៣១ និង៤១ នៃរដ្ឋធម្មនុញ្ញ។

**មាត្រា៣** ធានាសិទ្ធិសេរីភាពពីការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ។

**មាត្រា៤** ធានាពីការមិនអាចត្រូវបានផ្តន្ទាទោសចំពោះការបោះពុម្ពផ្សាយព័ត៌មានផ្លូវការដែលសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត។

**មាត្រា៥** ចែងអំពីសារព័ត៌មានមានសិទ្ធិទទួលបានព័ត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាល។

**មាត្រា២០** ជានាថាគ្មានជនណាម្នាក់ត្រូវប្រឈមនឹងការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារការបញ្ចេញមតិឡើយ។

### ១.២.៣ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

នាពេលថ្មីៗនេះ ក្រសួងព័ត៌មានបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ហើយកំពុងរង់ចាំការពិនិត្យ និងគាំទ្រពីក្រសួងយុត្តិធម៌។[1] ច្បាប់នេះមានគោលបំណងធានាដល់សិទ្ធិរបស់សាធារណជនក្នុងការទទួលព័ត៌មានពីស្ថាប័នសាធារណៈ។ ច្បាប់ថ្មីនេះទទួលបានការស្វាគមន៍ ព្រោះមាត្រា១៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លើកទឹកចិត្តយ៉ាងពេញទំហឹងឱ្យរដ្ឋភាគីបង្កើតច្បាប់សេរីភាពខាងព័ត៌មាន។[2]

ភាគីជាច្រើនបានចូលរួមក្នុងការព្រាងច្បាប់នេះ រួមទាំងអង្គការសង្គមស៊ីវិល អង្គការយូណេស្កូ និងស្ថាប័នផ្សព្វផ្សាយពាក់ព័ន្ធ[3] ដែលជាគំរូដ៏ល្អនៃដំណើរការតាក់តែងច្បាប់។

## ២. ស្ថាប័នសាធារណៈ និងភាតព្វកិច្ចរបស់ខ្លួនក្រោមគោលការណ៍នៃសិទ្ធិទទួលព័ត៌មាន

សិទ្ធិទទួលព័ត៌មានអនុវត្តចំពោះជនគ្រប់រូប ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។

### ២.១ តើស្ថាប័នសាធារណៈជាអ្វី ហើយព័ត៌មានប្រភេទណាដែលត្រូវតែបញ្ចេញ?

ស្ថាប័នសាធារណៈគួររាប់បញ្ចូលស្ថាប័នគ្រប់ជាន់ថ្នាក់របស់រដ្ឋាភិបាលដូចជាស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ។ ស្ថាប័នទាំងនោះរួមបញ្ចូលទាំងរដ្ឋបាលថ្នាក់មូលដ្ឋាន ស្ថាប័នជ្រើសតាំងតាមរយៈការបោះឆ្នោត ស្ថាប័នដែលត្រូវបានបង្កើតឡើងក្រោមលក្ខន្តិកៈច្បាប់ ឧស្សាហកម្ម ឬសាជីវកម្មសាធារណៈជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលទទួលជំនួយពីរដ្ឋាភិបាល និងស្ថាប័នឯកជនដែលបំពេញមុខងារសាធារណៈ។




---

[1] ស សុជាតិ "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានរងចាំការយល់ព្រមពីក្រសួងយុត្តិធម៌" (សារព័ត៌មានខ្មែរថ្មីស ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២១)។

[2] សេចក្តីពន្យល់ទូទៅលេខ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃ អ.ស.ប កថាខណ្ឌទី១៩។

[3] សេន ដេវីដ "សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានរួចរាល់នៅដំណាច់ឆ្នាំ" (សារព័ត៌មានខ្មែរថ្មីស ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២០)។

មិនគួរមានស្ថាប័នសាធារណៈណាមួយត្រូវលើកលែងពីការអនុវត្តសិទ្ធិទទួលព័ត៌មាននោះឡើយ។

ព័ត៌មានដែលស្ថាប័នសាធារណៈគួរតែបង្ហាញ៖

- ព័ត៌មានអំពីសកម្មភាព និងប្រតិបត្តិការរបស់ស្ថាប័នសាធារណៈ
- ព័ត៌មានអំពីសំណើ បណ្ដឹង ឬសកម្មភាពផ្ទាល់ដែលសាធារណជនអាចចូលរួមពាក់ព័ន្ធនឹង ស្ថាប័នសាធារណៈ
- ប្រភេទនៃព័ត៌មានដែលស្ថាប័នកំពុងគ្រប់គ្រង
- ការណែនាំអំពីការចូលរួមរបស់សាធារណជនក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និង
- ខ្លឹមសារនៃការសម្រេចចិត្តណាមួយដែលប៉ះពាល់ជាសាធារណៈ ដោយបញ្ជាក់ពីហេតុផលនៅពីក្រោយការសម្រេចចិត្តនេះ។

## ២.២ គោលការណ៍នៃសិទ្ធិទទួលព័ត៌មាន



### ១. ការបញ្ចេញព័ត៌មានជាអតិបរមា

រាល់ព័ត៌មានទាំងអស់ដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈគួរតែដាក់បង្ហាញដោយបើកចំហ លើកលែងតែក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ (សូមមើលគោលការណ៍ទី៤)។

### ២. កាតព្វកិច្ចក្នុងការផ្សព្វផ្សាយ

ស្ថាប័នសាធារណៈគួរតែផ្សព្វផ្សាយ និងចែកចាយឱ្យបានទូលំទូលាយនូវព័ត៌មានដែលជាផលប្រយោជន៍សាធារណៈសំខាន់ៗ។ ភាពជោគជ័យនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានវាស់វែងបានតាមរយៈចំនួននៃសំណើសាធារណៈដែលបានស្នើឡើង និងចម្លើយឆ្លើយតប និងតាមរយៈចំនួនព័ត៌មានដែលផ្សាយដល់សាធារណជន។

### ៣. ការលើកកម្ពស់ឱ្យមានរដ្ឋាភិបាលបើកចំហ

ស្ថាប័នសាធារណៈត្រូវតែលើកកម្ពស់យ៉ាងសកម្មនូវរដ្ឋាភិបាលបើកចំហមួយ តាមរយៈការអប់រំសាធារណជនអំពីសិទ្ធិរបស់ពួកគេ និងលើកកម្ពស់វប្បធម៌បើកចំហនៅក្នុងរដ្ឋាភិបាលដោយលុបបំបាត់កិច្ចការសម្ងាត់ជាផ្លូវការ។

### ៤. កម្រិតវិសាលភាពនៃការលើកលែង

ការលើកលែងមិនផ្តល់តាមសំណើសុំព័ត៌មានគួរតែមានលក្ខណៈច្បាស់លាស់ និងចង្អៀតបំផុត។ ព័ត៌មានគួរត្រូវបាត់ទុកជាការសម្ងាត់ ដរាបណាមានព័ត៌មានអាចបញ្ជាក់បានថាការលាតត្រដាងនឹងបង្កឱ្យអន្តរាយដល់សន្តិសុខជាតិ ឯកជនភាព ឬផលប្រយោជន៍ដែលត្រូវបានការពារដោយច្បាប់។ ការបដិសេធក្នុងការផ្តល់ព័ត៌មានគឺមិនសមហេតុផលទេ លុះត្រាតែអាជ្ញាធរអាចបញ្ជាក់បានថាព័ត៌មាននោះស្របតាមលក្ខខណ្ឌបីចំណុចខាងក្រោម៖

(១) ព័ត៌មានត្រូវតែពាក់ព័ន្ធនឹងគោលបំណងស្របច្បាប់ដែលមានចែងក្នុងច្បាប់

(២) ការបញ្ចេញព័ត៌មាននឹងគំរាមកំហែងនាំឱ្យមានអន្តរាយធ្ងន់ធ្ងរដល់គោលបំណងនោះ និង

(៣) ការអន្តរាយចំពោះគោលបំណងនោះត្រូវតែធំជាងផលប្រយោជន៍សាធារណៈក្នុងការទទួលព័ត៌មាន។

### ៥. ដំណើរការដើម្បីជួយសម្រួលដល់ការទទួលព័ត៌មាន

សំណើសុំព័ត៌មានរបស់សាធារណជនគួរតែត្រូវបានដំណើរការភ្លាមៗ និងដោយយុត្តិធម៌ ហើយការត្រួតពិនិត្រដោយឯករាជ្យ និងសិទ្ធិនៃបណ្តឹងតវ៉ាចំពោះការបដិសេធណាមួយគួរតែមាននៅក្នុងស្ថាប័នសាធារណៈនោះ។

### ៦. ការចំណាយ

មិនគួរមាននណាម្នាក់ត្រូវបានរារាំងពីការស្នើសុំព័ត៌មានដោយសារការចំណាយលើសលប់នោះឡើយ។ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលល្អនឹងមិនគិតថ្លៃសេវាចំពោះការដាក់ពាក្យស្នើសុំព័ត៌មាននោះទេ ប៉ុន្តែគិតតែតម្លៃក្នុងផ្តល់ឯកសារព័ត៌មានតែប៉ុណ្ណោះ ឧទាហរណ៍ ការថតចម្លងឯកសារជាដើម។

### ៧. កិច្ចប្រជុំបើកចំហ

កិច្ចប្រជុំរបស់ស្ថាប័នសាធារណៈគួរតែបើកចំហជាសាធារណៈ។ ប្រជាពលរដ្ឋគួរតែមានសិទ្ធិក្នុងការចូលរួមប្រជុំ និងជជែកពិភាក្សាជាសាធារណៈដើម្បីដឹងពីរបៀបនៃការសម្រេចចិត្តដោយតំណាង និងដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តផងដែរ។

### ៨. អាទិភាពនៃការបញ្ចេញព័ត៌មាន

រាល់ច្បាប់ជាតិណាមួយដែលមិនសមស្របនឹងគោលការណ៍នៃការបញ្ចេញព័ត៌មានជាអតិបរមា (គោលការណ៍ទី១) គួរតែធ្វើសោធនកម្ម ឬលុបចោល។

### ៩. ការការពារអ្នកបញ្ចេញព័ត៌មាន

បុគ្គលម្នាក់ៗគួរតែត្រូវបានការពារពីការដាក់ទណ្ឌកម្មផ្នែកច្បាប់ រដ្ឋបាល ទណ្ឌកម្មពាក់ព័ន្ធនឹងការងារ និងពីទុក្ខទោសនានាដោយសារការបញ្ចេញព័ត៌មានពីការប្រព្រឹត្តខុសដោយស្ថាប័នសាធារណៈ ឬឯកជន។

## ៣. ទំនាក់ទំនងរវាងសិទ្ធិទទួលព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិ



សិទ្ធិទទួលព័ត៌មានស្ថិតនៅក្នុងក្របខ័ណ្ឌទូទៅនៃសេរីភាពខាងការបញ្ចេញមតិ។ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពព័ត៌មានគឺជាសិទ្ធិមូលដ្ឋានដែលត្រូវបានធានាក្រោមច្បាប់ជាតិកម្ពុជា និងអន្តរជាតិ។ សេរីភាពសារព័ត៌មានក៏ជាធាតុដ៏សំខាន់នៃសិទ្ធិទាំងនេះផងដែរ។

សិទ្ធិទទួលព័ត៌មានគឺជាសិទ្ធិដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ការរួមបញ្ចូលគ្នានៃសិទ្ធិទាំងនេះមានសារៈសំខាន់ចំពោះដំណើរការនៃប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យ ព្រោះសិទ្ធិទាំងនេះអនុញ្ញាតឱ្យបុគ្គលម្នាក់ៗអាចប្រមូលព័ត៌មាន និងបង្ហាញគំនិតរបស់ខ្លួនដើម្បីធ្វើឱ្យពិភពមួយទៅកន្លែងដែលកាន់តែមានសមធម៌។

## ៤. ហេតុអ្វីសិទ្ធិទទួលព័ត៌មានមានសារៈសំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់យើង?



សិទ្ធិទទួលព័ត៌មានសាធារណៈគឺជាសិទ្ធិសម្រាប់មនុស្សគ្រប់រូបក្នុងការទទួលព័ត៌មានដែលពួកគេត្រូវការដើម្បីធ្វើការជ្រើសរើសដោយសេរី និងរស់នៅដោយស្វ័យភាព។ បើមិនមានព័ត៌មាន ប្រជាពលរដ្ឋក៏មិនមានអំណាចដើម្បីធ្វើការសម្រេចចិត្តចំពោះរដ្ឋាភិបាល ឬជីវភាពប្រចាំថ្ងៃរបស់ខ្លួន ហើយក៏មិនមានលទ្ធភាព ចូលរួមក្នុងដំណើរការសម្រេចចិត្តដ៏ត្រឹមត្រូវផងដែរ។ លើសពីនេះទៅទៀត បើមិនមានសិទ្ធិទទួលព័ត៌មាន មិនអាចធ្វើឱ្យសង្គមដែលមានរដ្ឋាភិបាលមានគណនេយ្យភាព ឬប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយបានឡើយ។

### ៤.១ ការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ

សិទ្ធិទទួលព័ត៌មានអាចធ្វើឱ្យសង្គមចូលរួមចំណែកក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ដែលជាគោលការណ៍ស្នូលនៃលទ្ធិប្រជាធិបតេយ្យពេញលេញ។ តាមរយៈការទទួលបានព័ត៌មាន ប្រជាពលរដ្ឋកាន់តែមានចំណេះដឹង និងមានឥទ្ធិពលលើការសម្រេចចិត្តរបស់រដ្ឋាភិបាលតាមរយៈការបញ្ចេញមតិដោយបើកចំហជាសាធារណៈ។ អវត្តមាននៃសិទ្ធិទទួលព័ត៌មាននឹងនាំឱ្យមានការលំបាកក្នុងការពិភាក្សាដេញដោលផ្សេងៗ

### ៤.២ គណនេយ្យភាព

ការទទួលព័ត៌មានគឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះសកម្មភាព ឬគោលនយោបាយ និងការតាក់តែងច្បាប់របស់ខ្លួន។ ការទទួលព័ត៌មានអនុញ្ញាតឱ្យសង្គមទាំងមូលឃ្លាំមើលពីរបៀបដែលរដ្ឋាភិបាលអនុវត្តសកម្មភាពក្នុងបេសកកម្ម អាណត្តិ និងគោលដៅរបស់ខ្លួនដែលបានសន្យា។ លើសពីនេះទៅទៀត ការទទួលព័ត៌មានផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការនិយាយដោយបើកចំហ និងដោយសេរី ដើម្បីធានាថារដ្ឋាភិបាលធ្វើតាមសេចក្តីស្នើដែលបានដាក់ចេញរបស់ខ្លួន។

### ៤.៣ ឥទ្ធិពលលើការប្រឆាំងអំពើពុករលួយ

បើមិនមានសិទ្ធិទទួលព័ត៌មានទេនោះ នាំឱ្យរដ្ឋាភិបាលខ្វះតម្លាភាព ដែលជម្រុញនូវ បរិយាកាសមួយដែលមានលក្ខណៈសម្ងាត់ និងអំពើពុករលួយ។ តាមរយៈការបង្កើននូវតម្លាភាព ការទទួលព័ត៌មានដើរតួនាទីជាមធ្យោបាយដ៏មានអានុភាពមួយក្នុងការស្វែងរក និងលាតត្រដាងការប្រព្រឹត្តអំពើពុករលួយដោយភាគីរដ្ឋាភិបាល និងឯកជន និងធ្វើឱ្យសង្គមមួយមានមុខងារល្អប្រសើរជាងមុន។

### ៤.៥ ការអភិវឌ្ឍ

ការទទួលព័ត៌មានផ្តល់សិទ្ធិអំណាចដល់ក្រុមងាយរងគ្រោះ និងក្រុមជួបការលំបាក ឱ្យចូលរួមកាន់តែច្រើនក្នុងការអភិវឌ្ឍនូវគំនិតផ្តួចផ្តើមផ្សេងៗដែលផ្តល់ផលល្អទៅលើពួកគេ។ កង្វះព័ត៌មានរារាំងក្រុមទាំងនេះពីលទ្ធភាពក្នុងការចូលរួមការអភិវឌ្ឍរបស់ខ្លួនដែលធ្វើឱ្យពួកគេរងគ្រោះឥតឈប់ឈរដោយសារតែគោលនយោបាយរបស់រដ្ឋាភិបាល។ នៅពេលដែលក្រុមទាំងនេះទទួលបានព័ត៌មាន ពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម ហើយពួកគេអាចតទល់នឹងបទដ្ឋាន និងមនោគមវិជ្ជាដែលគ្រោះថ្នាក់បាន។

## ៥. តើព័ត៌មានប្រភេទណាដែលប្រជាពលរដ្ឋអាចស្នើសុំបាន?

ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នសាធារណៈ

គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័ន

ព័ត៌មានលម្អិតអំពីយន្តការផ្តល់សេវាកម្ម

ច្បាប់ បទបញ្ញត្តិ គោលនយោបាយ សេចក្តីសម្រេច និងភារកិច្ចរបស់ស្ថាប័នសាធារណៈពាក់ព័ន្ធនឹងសិទ្ធិ សេរីភាព កាតព្វកិច្ច និងផលប្រយោជន៍សាធារណៈ

រាល់ទិដ្ឋភាពនៃការប្រព្រឹត្តទៅនៃស្ថាប័នសាធារណៈ និងនីតិវិធីនៅតុលាការ រួមទាំងកិច្ចការរដ្ឋបាលដែលជាផលប្រយោជន៍របស់សាធារណៈ និងដែលមានទំនាក់ទំនងផ្ទាល់ជាមួយសាធារណជន និង

គម្រោងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ និងរបាយការណ៍ចំណាយប្រចាំឆ្នាំ និងសវនកម្មរបស់ខ្លួន

## ៦. តើរដ្ឋអាចការពារសិទ្ធិទទួលព័ត៌មានដោយរបៀបណា?



សិទ្ធិទទួលព័ត៌មានមិនត្រឹមតែមានសារៈសំខាន់ក្នុងការអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងបើកចំហប៉ុណ្ណោះទេ ប៉ុន្តែក៏អនុញ្ញាតឱ្យមានការជជែកដេញដោលជាសាធារណៈអំពីបញ្ហាសំខាន់ៗ និងផលប្រយោជន៍សារធារណៈនានាដែលប៉ះពាល់ដល់ជីវភាពប្រជាជនផងដែរ។ សិទ្ធិនេះក៏មានសារៈប្រយោជន៍ផងដែរក្នុងការអនុវត្តសិទ្ធិផ្សេងទៀត។ រដ្ឋាភិបាលត្រូវតែគោរពសិទ្ធិទទួលព័ត៌មានដោយមិនរំលោភទៅលើសិទ្ធិនេះដោយផ្ទាល់តាមរយៈការអនុម័តច្បាប់ គោលនយោបាយ ឬតាមរយៈសេចក្តីសម្រេចបែបរឹតបន្តឹងរបស់តុលាការ។ លើសពីនេះទៅទៀត រដ្ឋាភិបាលត្រូវតែការពារយ៉ាងសកម្មនូវសិទ្ធិទទួលព័ត៌មានតាមរយៈការអនុម័តច្បាប់ ឬគោលនយោបាយដែលការពារសិទ្ធិយ៉ាងហ្មត់ចត់ ។ ជាងនេះទៅទៀត រដ្ឋាភិបាលគួរតែរារាំងបុគ្គលផ្សេងទៀតពីការ

រំលោភលើសិទ្ធិទទួលព័ត៌មាន ដោយបង្កើតយន្តការការពារនៅក្នុងស្ថាប័នរដ្ឋាភិបាលដល់បុគ្គលនានា ដើម្បីបន្តយន្តការតវ៉ាដោយឯករាជ្យ ជុំវិញការមិនបានទទួលព័ត៌មាន។



រដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ព័ត៌មានតាមការស្នើសុំ ក៏ដូចជាធ្វើការផ្សព្វផ្សាយ និងចែកចាយឱ្យបានទូលំទូលាយនូវព័ត៌មានដែលមានសារៈសំខាន់ជាសាធារណៈ ដូចជាព័ត៌មានដែលអាចជួយការពារ និងអនុវត្តសិទ្ធិនយោបាយ សិទ្ធិមនុស្ស ឬអាចបង្ហាញអំពើពុករលួយនៅក្នុងរដ្ឋាភិបាល។ កាតព្វកិច្ចជាច្រើនរបស់រដ្ឋាភិ បាលដែលអាចត្រូវកំណត់ពាក់ព័ន្ធនឹងសិទ្ធិនេះ។

## ៧. តើសិទ្ធិទទួលព័ត៌មានអាចលើកកម្ពស់ និងការពារសិទ្ធិដទៃផ្សេងទៀតបានដោយរបៀបណា?

សិទ្ធិទទួលព័ត៌មានគឺជាសិទ្ធិមួយប៉ុន្តែក៏ជាធាតុសំខាន់នៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិផងដែរ។ សិទ្ធិសេរីភាពខាងការបញ្ចេញមតិគឺជាច្រកផ្លូវដែលផ្តល់លទ្ធភាពក្នុងការអនុ វត្តសិទ្ធិផ្សេងទៀត។ ជាឧទាហរណ៍ សង្គមមួយត្រូវការសិទ្ធិទទួល ព័ត៌មានដើម្បីតាមដានការអនុវត្តសិទ្ធិជាមូលដ្ឋានផ្សេងទៀត។ សិទ្ធិទទួលព័ត៌មានអនុញ្ញាតិឱ្យបុគ្គលយល់ដឹងអំពីគោលនយោបាយសាធារណៈ ឬសកម្មភាពនានាពាក់ព័ន្ធនឹងសិទ្ធិជាក់លាក់ណាមួយ រួមទាំងសិទ្ធិទទួលបានសុខមាលភាព សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិឯកជនភាព និងជីវិតគ្រួសារ និងសិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួនជាដើម។ សិទ្ធិទទួលព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិផ្សេងទៀតដោយសារៈ

**ជាធាតុសំខាន់សម្រាប់ការទទួលស្គាល់សិទ្ធិផ្សេងទៀត**

**ផ្តល់ប្រសិទ្ធភាព និងការពារសិទ្ធិផ្សេងទៀត**

**ជួយដល់ការអនុវត្តសិទ្ធិផ្សេងទៀតតាមរយៈតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល និង**

**ទប់ស្កាត់ការរំលោភបំពានបន្ថែមទៀតតាមរយៈការអប់រំជាសាធារណៈ និងឱ្យសាធារណជនមានចំណេះដឹងអំពីស្ថានភាពនៃផលប្រយោជន៍សាធារណៈសំខាន់ៗ។**

## សំណួរសាកល្បង

**១. តើអ្វីជាសិទ្ធិទទួលព័ត៌មាន?**

☐ ក. សិទ្ធិទទួលព័ត៌មាន មិនមានទំនាក់ទំនងជាមួយសិទ្ធិសេរីភាពនៃការបញ្ចេញមតិទេ ហើយសិទ្ធិនេះផ្តោតតែលើការចែកចាយព័ត៌មានប៉ុណ្ណោះ។

☐ ខ. សិទ្ធិទទួលព័ត៌មាន គឺជាផ្នែកមួយនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងការស្វែងរក ទទួល និងចែកចាយព័ត៌មាន និងគំនិតនានា

☐ ចម្លើយ ក និង ខ

**២. សិទ្ធិទទួលព័ត៌មានអាចបង្ហាញចេញជាពីរទម្រង់៖**

☐ ក. សកម្ម និងប្រតិកម្ម

☐ ខ. សកម្ម និងអកម្ម

☐ គ. មិនមែនចម្លើយទាំងអស់ខាងលើ

**៣. "សកម្ម" ទម្រង់នៃសិទ្ធិទទួលព័ត៌មានដែលកំណត់កាតព្វកិច្ចជាវិជ្ជមានរបស់ស្ថាប័នសាធារណៈក្នុងការផ្តល់ឱ្យបោះពុម្ពផ្សាយ និងផ្សព្វផ្សាយព័ត៌មានដែលមានសារៈសំខាន់ដល់សាធារណជន។**

☐ ក. ត្រូវ

☐ ខ. ខុស

**៤. "ប្រតិកម្ម" ផ្នែកនៃសិទ្ធិទទួលព័ត៌មានដែលអនុញ្ញាតឱ្យបុគ្គលគ្រប់រូបស្វែងរក ស្នើសុំ និងទទួលព័ត៌មានពីមន្ត្រីសាធារណៈអំពីភារកិច្ចដែលពួកគេកំពុងអនុវត្ត និងឯកសារទាំងឡាយដែលពួកគេមាន។**

☐ ក. ត្រូវ

☐ ខ. ខុស

**៥. តើមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញផ្តល់ធម្មនុញ្ញភាពដល់សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន ដែលភាគច្រើនមានចែងអំពីសិទ្ធិទទួលព័ត៌មាន?**

☐ ក. មាត្រា ៣០

☐ ខ. មាត្រា ៣១

☐ គ. មាត្រា ៤១

**៦. តើព័ត៌មានអ្វីខ្លះដែលស្ថាប័នសាធារណៈគួរតែបង្ហាញ?**

☐ ក. ព័ត៌មានអំពីសកម្មភាព និងប្រតិបត្តិការរបស់ស្ថាប័នសាធារណៈ

☐ ខ. ព័ត៌មានអំពីសំណើ បណ្តឹង ឬសកម្មភាពផ្ទាល់ដែលសាធារណជនអាចចូលរួមពាក់ព័ន្ធនឹងស្ថាប័នសាធារណៈ

☐ គ. ប្រភេទនៃព័ត៌មានដែលស្ថាប័នកំពុងគ្រប់គ្រង និងការណែនាំអំពីការចូលរួមរបស់សាធារណជនក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត

☐ ឃ. ខ្លឹមសារនៃការសម្រេចចិត្តណាមួយដែលប៉ះពាល់ជាសាធារណៈ ដោយបញ្ជាក់ពីហេតុផលនៅពីក្រោយការសម្រេចចិត្តនេះ

☐ ង. ចម្លើយ ក, ខ, គ និង ឃ

**៧. គោលការណ៍មួយនៃសិទ្ធិទទួលព័ត៌មានបានលើកឡើងថា "ស្ថាប័នសាធារណៈត្រូវតែលើកកម្ពស់យ៉ាងសកម្មនូវរដ្ឋាភិបាលបើកចំហមួយ តាមរយៈការអប់រំសាធារណជនអំពីសិទ្ធិរបស់ពួកគេ និងលើកកម្ពស់វប្បធម៌បើកចំហនៅក្នុងរដ្ឋាភិបាលដោយលុបបំបាត់កិច្ចការសម្ងាត់ជាផ្លូវការ"។**

☐ ក. ត្រូវ

☐ ខ. ខុស

**៨. សិទ្ធិទទួលព័ត៌មាន គឺជាសិទ្ធិដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ការរួមបញ្ចូលគ្នានៃសិទ្ធិទាំងនេះមានសារៈសំខាន់ចំពោះដំណើរការនៃប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យ ព្រោះសិទ្ធិទាំងនេះអនុញ្ញាតឱ្យបុគ្គលប្រមូលព័ត៌មាន និងនិយាយពីអ្វីដែលមានក្នុងគំនិតរបស់ពួកគេ។**

☐ ក. ត្រូវ

☐ ខ. ខុស

**៩. ហេតុអ្វីសិទ្ធិទទួលព័ត៌មានមានសារៈសំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់យើង?**

☐ ក. សិទ្ធិទទួលព័ត៌មាន ជួយឱ្យមនុស្សគ្រប់រូបទទួលព័ត៌មានដែលពួកគេត្រូវការដើម្បីធ្វើការជ្រើសរើសដោយសេរី និងរស់នៅដោយស្វ័យភាព

☐ ខ. សិទ្ធិទទួលព័ត៌មាន ជួយឱ្យប្រជាពលរដ្ឋអាចធ្វើការសម្រេចចិត្តចំពោះរដ្ឋាភិបាល ឬការរស់នៅប្រចាំថ្ងៃរបស់ខ្លួន និងមានលទ្ធភាពចូលរួមក្នុងដំណើរការសម្រេចចិត្តដ៏ត្រឹមត្រូវផងដែរ

☐ គ. សិទ្ធិទទួលព័ត៌មាន អាចធ្វើឱ្យសង្គមដែលមានរដ្ឋាភិបាលមានគណនេយ្យភាព ឬលុបបំបាត់អំពើពុករលួយបាន

☐ ឃ. ចម្លើយ ក, ខ និង គ

**១០. តើរដ្ឋអាចការពារសិទ្ធិទទួលព័ត៌មានដោយរបៀបណា?**

☐ ក. មិនត្រូវរំលោភបំពានសិទ្ធិនេះដោយផ្ទាល់តាមរយៈការអនុម័តច្បាប់ គោលនយោបាយ ឬការរឹតត្បិតតាមរយៈការសម្រេចរបស់តុលាការ

☐ ខ. អនុម័តច្បាប់ ឬគោលនយោបាយដែលការពារសិទ្ធិនេះឱ្យបានច្បាស់លាស់

☐គ. ផ្តល់កិច្ចការការពារនៅក្នុងស្ថាប័នរដ្ឋាភិបាលសម្រាប់បុគ្គលគ្រប់រូបទទួលបានយន្តការបណ្តឹងដោយឯករាជ្យក្នុងករណីដែលមិនបង្ហាញព័ត៌មាន

☐ ឃ. ចម្លើយ ក, ខ និង គ